# ដំណើរការតាក់តែងច្បាប់

## ក) ធាតុគន្លឹះនៃដំណើរការតាក់តែងច្បាប់

### I) ការដាក់ឱ្យពិនិត្យលើពង្រាងច្បាប់* :

ការផ្តួចផ្តើមធ្វើច្បាប់ មានន័យថា ជាការដាក់ឱ្យពិនិត្យលើពង្រាងសំណើនានា

- ដើម្បីធ្វើការអនុម័តលើច្បាប់ថ្មីមួយចំនួន
  ឬ
- ដើម្បីធ្វើវិសោធនកម្មលើច្បាប់នៅជាធរមាន

ស្ថាប័នចំនួនបីផ្សេងគ្នាដែលមាន**សិទ្ធិផ្តួចផ្តើមធ្វើច្បាប់** ( មាត្រា៩១ I CC):

- សមាជិកសភាម្នាក់ៗ
- រដ្ឋាភិបាល
- សមាជិកម្នាក់ៗនៃព្រឹទ្ធសភា

ពង្រាងច្បាប់នីមួយៗ ត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនៈ (ប្រការ ២១ និង ២២ នៃបទបញ្ជាផ្ទៃក្នុងសភាជាតិ):

ពង្រាងច្បាប់ត្រូវៈ

- សរសេរជាលាយលក្ខណ៍អក្សរ
- បែងចែកចេញជាមាត្រា
- រួមបញ្ចូលទាំង"**សេចក្តីថ្លែងហេតុ**" (=មូលហេតុនៃពង្រាងច្បាប់)
- មិនមានគោលបំណងក្នុងការកាត់បន្ថយចំណូលសាធារណៈទេ ឬ
- តែ**ស្របនឹងរដ្ឋធម្មនុញ្ញ** ( មាត្រា១៤០-១៤២ CC) ។

### II) ភាពចាំបាច់នៃជំនាញការពិសេស

ការដាក់ឱ្យពិនិត្យ និងពិភាក្សាលើពង្រាងច្បាប់នានា ដែលបំពេញលក្ខខណ្ឌទាំងនេះ ជាការងារពិបាកមួយ ។ វាទាមទារឱ្យមានសមាសភាពពីរសំខាន់ៗ:

- ជំនាញការលើមុខវិជ្ជាពិសេសដែលច្បាប់ត្រូវបញ្ញត្តិ
  និង
- ចំណេះដឹងផ្នែកច្បាប់ នៅក្នុងការបង្កើតច្បាប់ ។

* កំណត់សំគាល់: ពាក្យថា "ពង្រាងច្បាប់" នៅក្នុងសៀវភៅនេះ ជាពិសេសនៅក្នុងមេរៀនផ្នែកនេះ មានន័យសំដៅដល់ទាំង សេចក្តីស្នើច្បាប់ដែលធ្វើឡើងដោយអង្គនីតិបញ្ញត្តិ និងសេចក្តីព្រាងច្បាប់ដែលធ្វើឡើងដោយអង្គនីតិប្រតិបត្តិ ។

ដូចជា ពង្រាងច្បាប់នេសាទ ទាមទារឱ្យមាន**ជំនាញការពិសេស និងការយល់ដឹង**អំពីបញ្ហាពាក់ព័ន្ធនឹងសេដ្ឋកិច្ច សង្គម និងបរិស្ថាន ក្នុងវិស័យនេសាទ ។ បញ្ហាទាំងនោះ ត្រូវតែកំណត់ឱ្យឃើញ និងដំណោះស្រាយបញ្ហាផ្សេងៗដែលអាចធ្វើទៅបាន ត្រូវតែបង្កើតឡើង និងពិភាក្សាឱ្យបានទូលំទូលាយ ។ ដូច្នេះ គោលនយោបាយត្រូវតែបង្កើតឡើង ។

លើសពីនេះទៅទៀត ការធ្វើច្បាប់ទាមទារឱ្យមាន**ការយល់ដឹងពិសេសផ្នែកច្បាប់** អំពីថាតើត្រូវធ្វើការបកស្រាយយ៉ាងណានៅក្នុងអត្ថបទច្បាប់ ចំពោះការបង្កើតគោលនយោបាយ និង ដំណោះស្រាយបញ្ហាប្រសើរមួយ ។ ច្បាប់នីមួយៗ ត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជាដទៃទៀត ។ ការត្រួតពិនិត្យលើភាពសមស្របនេះ ទាមទារបន្ថែមនូវចំណេះដឹងផ្នែកច្បាប់ ។

ជាការពិតណាស់ មិនមែនសមាជិកសភាទាំង ១២៣នាក់នោះទេ ដែលអាចមានជំនាញពិសេស និងការយល់ដឹងអំពីប្រធានបទ និងវិស័យផ្សេងៗ ដែលត្រូវបញ្ញត្តិដោយច្បាប់មួយ (ដូចជា ហិរញ្ញវត្ថុ ការអប់រំ សុខភាព ឧក្រិដ្ឋកម្ម វិស័យតុលាការ ការការពារបរិស្ថាន ។ល។) ។ ជាងនេះទៅទៀត សមាជិកសភាភាគច្រើន មិនមែនជាអ្នកច្បាប់ និងមិនមានចំណេះដឹងផ្នែកច្បាប់ទេ ។

## III) ការត្រួតពិនិត្យជាទូទៅលើពង្រាងច្បាប់ដោយតួអង្គផ្សេងៗ និងស្ថាប័នជំនាញ

១) ចំពោះហេតុផលមួយចំនួនដែលបានបញ្ជាក់នៅខាងលើ វាជា**ការចាំបាច់**ដែលថា សមាជិកសភាមួយចំនួន**មានជំនាញលើវិស័យផ្សេងៗគ្នា** ហើយ**រួមបញ្ចូលជំនាញពិសេស** និងចំណេះដឹងរបស់ពួកគេទៅក្នុង**គណៈ-កម្មការផ្សេងៗ** ដែលធ្វើការលើវិស័យជាក់លាក់ទាំងនោះ ។ បច្ចុប្បន្ននេះ មានគណៈកម្មការចំនួន ៩ (សូមមើលឧបសម្ព័ន្ធ)[៥] ។

គណៈកម្មការទាំងនេះ អាចផ្តល់អនុសាសន៍នានា នៅពេលប្រជុំពេញអង្គនៃសមាជិកសភាទាំងអស់ ថាតើត្រូវធ្វើយ៉ាងណាចំពោះពង្រាងមួយ ។ ជាការពិតណាស់ អំណាចនៃ**ការពិភាក្សាចុងក្រោយ** និង**ការអនុម័តលើអត្ថបទពង្រាង** រក្សានូវ**ការទទួលខុសត្រូវរបស់អ្នកតាក់តែងច្បាប់ទាំងអស់** ដែលត្រូវពិចារណាលើសំណើ និងជំរើសនានា និងត្រូវស្វែងរកដំណោះស្រាយដ៏ប្រសើរបំផុតមួយតាមរយៈការពិភាក្សា និងការប្រៀបធៀបលើជំរើសទាំងនោះ ។ ដូចដែលបានបង្ហាញខាងលើមកហើយថា បច្ចេកទេសនៃដំណើរការពង្រាងច្បាប់ អាចទាមទារឱ្យមានការចូលរួមរបស់អ្នកដែលមានជំនាញខ្ពស់ ។ ប៉ុន្តែ អ្នកតាក់តែងច្បាប់ទាំងអស់ ត្រូវធ្វើការសំរេចចុងក្រោយក្នុងនាមប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដោយមិនគិតថាអ្នកតាក់តែងច្បាប់ទាំងនោះ មានជំនាញអ្វីមួយ ឬជាអ្នកច្បាប់ ឬមិនមែននោះទេ ។ ពួកគេគ្រាន់តែអាចប្រើអ្នកជំនាញការឱ្យផ្តល់នូវដំណោះស្រាយមួយចំនួន និងការប្រឹក្សាដល់ពួកគេប៉ុណ្ណោះ ។

[៥] បើអ្នកចង់ដឹងថាតើអ្នកតាក់តែងច្បាប់មួយណាធ្វើការនៅក្នុងគណៈកម្មការមួយណា សូមមើលគេហទំព័ររបស់រដ្ឋសភា: www.cambodian-parliament.org

**២**) ដោយសារតែការធ្វើពង្រាងច្បាប់ នៅមានការលំបាក តួអង្គផ្សេងៗ (រដ្ឋាភិបាល ព្រឹទ្ធសភា) ដែលអាចផ្ដួចផ្ដើមធ្វើពង្រាងច្បាប់ ក៏ប្រើប្រាស់នូវជំនាញសំរាប់ជាឧបករណ៍នៅក្នុងការដោះស្រាយបញ្ហា នៅមុនពេលដាក់ពង្រាងឱ្យពិនិត្យដែរ ។

ជាឧទាហរណ៍ **រដ្ឋាភិបាល**មានក្រសួងជំនាញផ្សេងៗដែលធម្មតាជាអ្នកធ្វើពង្រាងច្បាប់ ។ បន្ទាប់មកក្រុមប្រឹក្សាអ្នកច្បាប់ ធ្វើការត្រួតពិនិត្យ និងផ្ដល់ការពន្យល់លើពង្រាងនោះ ហើយនៅទីបញ្ចប់គណៈរដ្ឋមន្ត្រី ត្រូវធ្វើការអនុម័តលើពង្រាងច្បាប់ នៅមុនពេលដែលវាត្រូវដាក់ជូនគណៈកម្មការជំនាញរបស់សភា[១០] តាមរយៈគណៈ-កម្មាធិការអចិន្ត្រៃយ៍ ។

**ព្រឹទ្ធសភា** ក៏អាចដោះស្រាយបញ្ហាជាដំបូងជាមួយគណៈកម្មការរបស់ខ្លួនដែលពាក់ព័ន្ធ នៅមុនពេលដាក់ពង្រាងមួយ ទៅរដ្ឋសភាតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ។

៣) នៅពេលដែលរដ្ឋសភា បានអនុម័តពង្រាងច្បាប់រួចហើយ រដ្ឋធម្មនុញ្ញ តំរូវឱ្យមាន**ការពិនិត្យ**និងពន្យល់លើច្បាប់នោះ**ដោយព្រឹទ្ធសភា** ។ បន្ទាប់មក ច្បាប់អាចត្រូវបានអនុម័តដោយរដ្ឋសភាម្ដងទៀត ។

ដូច្នេះ **ដំណើរការតាក់តែងច្បាប់ទាំងមូល** ត្រូវបាន**សំគាល់ដោយការជាប់ទាក់ទងរបស់ស្ថាប័ន** និងអង្គភាពជំនាញមួយចំនួនធំ ។ ករណីនេះ ប្រហែលជាត្រូវការចំណាយពេលច្រើន ប៉ុន្តែ វានឹងធានាដល់គុណភាពនៃដំណើរការតាក់តែងច្បាប់ ។ គំនិតដែលនៅខាងក្រោយដំណើរការនេះ គឺថា ដំណោះស្រាយតាមផ្លូវច្បាប់ដែលល្អ និងស្ថិតស្ថេរ ចំពោះបញ្ហាមួយ ដែលមានចែងនៅក្នុងច្បាប់ថ្មី ឬវិសោធនកម្មច្បាប់ អាចត្រូវបានលើកឡើងនៅក្រោយពេល **ដំណើរការចូលរួម និងពិភាក្សាទូលំទូលាយមួយ** ។

## IV) ការប្រកាសឱ្យប្រើ និងការផ្សព្វផ្សាយច្បាប់៖

បន្ទាប់ពីការពិនិត្យ ផ្ដល់ការពន្យល់ និងពិភាក្សាមក និងនៅពេលដែលសភាបានអនុម័តជាចុងក្រោយនូវច្បាប់ថ្មីមួយ ឯកសារដើមនៃច្បាប់នេះ ត្រូវតែ**ឡាយព្រះហស្ដលេខាដោយព្រះមហាក្សត្រ** ។ នៅក្នុងករណីនេះ ព្រះមហាក្សត្រ មានតួនាទីដូចជា**សាការី**មួយ ដែលគ្រាន់តែត្រួតពិនិត្យឡើងវិញនូវទំរង់បែបបទដែលតំរូវឱ្យមាននោះត្រូវបានបំពេញគ្រប់អស់ហើយ ។ ការធ្វើដូចនេះគេហៅថា **ការប្រកាសឱ្យប្រើច្បាប់** ។ នៅទីបញ្ចប់ វាទាមទារឱ្យមាន**ការផ្សព្វផ្សាយ**ច្បាប់ ដើម្បីឱ្យច្បាប់នោះចូលជាធរមាន ពីព្រោះថាមានតែវិធានច្បាប់ដែលត្រូវបានអាន និងទទួលដឹងដោយប្រជាពលរដ្ឋគ្រប់រូបតែប៉ុណ្ណោះ ដែលមានអានុភាពអនុវត្តលើប្រជាពលរដ្ឋ ។

## V) ការត្រួតពិនិត្យមើលច្បាប់ដោយប្រព័ន្ធតុលាការ៖

នៅទីបញ្ចប់ មានលទ្ធភាពមួយដែល**ការត្រួតពិនិត្យរបស់តុលាការ**ទៅលើច្បាប់ ដើម្បីធានាភាពស្របនឹងរដ្ឋធម្មនុញ្ញៈ ធម្មនុញ្ញភាពនៃច្បាប់មួយ អាចត្រូវបានត្រួតពិនិត្យដោយ**ក្រុម-ប្រឹក្សាធម្មនុញ្ញ** (មាត្រា១៣៦-១៤៤ CC) នៅមុនពេលការប្រ-កាសឱ្យប្រើ និងការផ្សព្វផ្សាយច្បាប់ ។



[១០] ចំពោះពតិមានលំអិតអំពីនីតិវិធីរបស់រដ្ឋាភិបាល ចូរមើលៈ សៀវភៅរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រភពច្បាប់កម្ពុជា (Cambodia Legal Resource Development enter) "សេចក្ដីសង្ខេបលើច្បាប់កម្ពុជា" 2000 Volume III, I-23 A

## ខ) សេចក្តីសង្ខេបពីដំណើរការតាក់តែងច្បាប់



## ក) ដំណើរការលំអិតនៃការតាក់តែងច្បាប់



**ស ភា ជា តិ**

ផ្ញើច្បាប់អនុម័តរួចឱ្យទៅៈ

↓

**ព្រឹ ទ្ធ ស ភា**

(មាត្រា១១៣ I, II CC)

ពិនិត្យច្បាប់ដែលអនុម័តរួច ហើយអាចៈ

- អនុម័ត → មាត្រា១១៣ VIII CC
- កែប្រែច្បាប់ ឬ
- បដិសេធច្បាប់

ក្នុងរយៈពេល១ខែជាកំណត់ (ឬ៧ថ្ងៃនៅក្នុងករណី"ប្រញាប់")

↓

**ស ភា ជា តិ**

(មាត្រា១១៣ III CC)

១. ពិនិត្យច្បាប់ ។ សភាជាតិអាចៈ

- ទទួលយកការកែប្រែទាំងអស់ដែលស្នើដោយព្រឹទ្ធសភា → មាត្រា១១៣ VIII CC
- ទទួលយកមួយផ្នែកនៃការកែប្រែ
- បដិសេធសំណើរបស់ព្រឹទ្ធសភា

↓

**ព្រឹ ទ្ធ ស ភា**

ពិនិត្យច្បាប់ម្តងទៀត

↓

**ស ភា ជា តិ**

- ២. ពិនិត្យ ក្នុងករណីព្រឹទ្ធសភាបដិសេធច្បាប់ម្តងទៀត និង
- ការអនុម័តចុងក្រោយលើច្បាប់

↓

**ការ ប្រ កា ស ឱ្យ ប្រើ**

ច្បាប់ដែលបានអនុម័តរួច និងឡាយប្រហស្តលេខាដោយព្រះមហាក្សត្រ

(មាត្រា៩៣ I ១ CC)

↓

**ការ ប្រ កា ស ឱ្យ ប្រើ**

(មាត្រា៩៣ II CC)

## ឃ) ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់

អ្នកតាក់តែងច្បាប់ផ្ទាល់ ក៏ត្រូវតែគោរពរដ្ឋធម្មនុញ្ញកម្ពុជាដែរ ។ នេះមានន័យថា ពួកគេមិនអាចធ្វើច្បាប់ដែលមានលក្ខណៈបំពានដល់សិទ្ធិមនុស្ស ឬបទដ្ឋានច្បាប់ និងគោលការណ៍នានា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនោះទេ ។ ដូច្នេះ ច្បាប់ទាំងអស់អាចស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថាតើវាស្របនឹងរដ្ឋធម្មនុញ្ញ ដែរឬទេ ។

**មាត្រា៩២ CC:**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាល របស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសំរេចពីមោឃភាពនេះ ។

**មាត្រា១៣៦ I CC:**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ។

មានមធ្យោបាយច្រើនផ្សេងៗគ្នា ដែលតំរូវឱ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការត្រួតពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់ ។

**ការពិនិត្យច្បាប់**

(មាត្រា១៤០ I CC)

នៅមុនការប្រកាសឱ្យប្រើច្បាប់

- ព្រះមហាក្សត្រ
- នាយករដ្ឋមន្ត្រី
- ប្រធានសភាជាតិ
- សមាជិកសភា ១/១០
- ប្រធានព្រឹទ្ធសភា
- សមាជិកព្រឹទ្ធសភា ១/៤

អាចបញ្ជូនពង្រាងច្បាប់ដែលបានឆ្លងសភារួចហើយ ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យមុនពេលប្រកាសឱ្យប្រើ ។

**ការត្រួតពិនិត្យច្បាប់**

(មាត្រា១៤១ CC)

បន្ទាប់ពីការប្រកាសឱ្យប្រើ

**ប្រជាពលរដ្ឋ**

អាចប្តឹងឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់

(មាត្រា ១៤១ II CC, មាត្រា១៩ នៃច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**តាមរយៈ**

- សមាជិកសភា
- ប្រធានសភា
- សមាជិកព្រឹទ្ធសភា
- ប្រធានព្រឹទ្ធសភា
- តុលាការ

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានសភា
- នាយករដ្ឋមន្ត្រី
- សមាជិកព្រឹទ្ធសភា ១/១០
- សមាជិកសភា ១/១០
- តុលាការនីមួយៗ

អាចស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើរួចហើយ (មាត្រា១៤១ I CC)

## ? សំនួរសិក្សាទី ៣

ចូរអានអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារពត៌មាន The Cambodian Daily ចេញផ្សាយ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣:

មិនមែនត្រឹមតែ សមាជិកគណបក្សសមរង្ស៊ីប៉ុណ្ណោះទេ ប៉ុន្តែ សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា លោកស្រី ជា វណ្ណាត (នាយកមជ្ឈមណ្ឌលអភិវឌ្ឍសង្គម) និង លោក ឡៅ ម៉ុងហៃ (អ្នកវិភាគនយោបាយ) អះអាងថា ការពិភាក្សានៅក្នុងសភាជាតិ មិនចេញឆ្ងាយពីគោលការណ៍របស់គណបក្សនយោបាយទេ ហើយកំរនឹងពិចារណាដល់ផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូលណាស់ និងទំនងដូចជា "ការសំរេចតែម្នាក់ឯង" ។ ការរិះគន់នេះ ត្រូវបានបដិសេធដោយសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា ដូចជា លោក ជៀម យៀប និង មកពីគណបក្សហ៊្វុនស៊ិនប៉ិច ដូចជា ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធ ដោយបញ្ជាក់ថា វប្បធម៌នៃលទ្ធិប្រជាធិបតេយ្យ ហាក់មានការរីកចំរើនខ្លះហើយនៅក្នុងសភា ហើយមានក៏រិតអនុវត្តខ្ពស់ជាងឆ្នាំមុនៗ បើយើងប្រៀបធៀបនៅក្រោយឆ្នាំ១៩៩៧ នៅពេលដែលមានការប្រឆាំងគ្នារវាងបក្សពួក មានតែសមាជិកសភាតែម្នាក់ប៉ុណ្ណោះដែលជាអ្នកមានគំនិតប្រឆាំងតវ៉ា ។ ដើម្បីបង្កើនគុណភាពការងាររបស់សភា គឺត្រូវស្នើឱ្យពង្រីកនូវចំនួនអ្នកជំនាញបច្ចេកទេសនៅក្នុង គណៈកម្មការសភា និងដើម្បីបង្កើតអនុគណៈកម្មការ ។

ហេតុអ្វីបានជាអ្នកគិតថា គួរតែមានសំណើរបស់ព្រះអង្គម្ចាស់ រណឫទ្ធ នៅក្នុងអត្ថបទខាងលើនេះ បង្កើនគុណភាពការងាររបស់សភាជាតិ?